សំរេច

មាត្រា ១ : តែងតាំងព្រះអង្គម្ចាស់ក្សត្រីយ៍ សម្តេចព្រះរាម បុប្ផាទេវី ជាអ្នកទទួលខុសត្រូវផ្ទាល់ចំពោះក្រុមរបាំព្រះរាជទ្រព្យ (ក្រុមរបាំព្រះបរមរាជវាំង) ដោយធ្វើការហាត់ហ្វឹកហ្វឺនរៀនសូត្រ នៅក្នុងព្រះបរមរាជវាំង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួល បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈរដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួងរដ្ឋលេខាធិការអនុរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន និងព្រះអង្គម្ចាស់ក្សត្រីយ៍ សម្តេចព្រះរាមអនុវត្តតាមអនុក្រឹត្យនេះចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

# ២-សេចក្តីសំរេច

*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ១៩៩៤*

## សេចក្តីសំរេចលេខ ១២០ សសរ
## ស្តីពីការបង្កើតគណៈកម្មការអ្នកជំនាញឯករទេស
## អំពីបញ្ហាអណិកជនវៀតណាម

* * *

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីអន្តោប្រវេសន៍ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤

-តាមសំណូមពរការងារចាំបាច់

**សំរេច**

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការមួយ ឈ្មោះគណៈកម្មការ អ្នកជំនាញឯកទេស អំពីបញ្ហាអាណិកជនវៀតណាម ដែលមានសមាសភាពដូចខាងក្រោម ៖

១-តំណាងក្រសួងមហាផ្ទៃ ជាប្រធាន

២-តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៣-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៤-តំណាងក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ជាសមាជិក

ប្រការ ២ : គណៈកម្មការអ្នកជំនាញឯកទេសអំពីអាណិកជនវៀតណាម មានភារកិច្ចពន្យល់ភាគីវៀតណាមអំពីការបកស្រាយនូវច្បាប់ ស្តីពីអន្តោប្រវេសន៍ ដែលបកាសអោយប្រើដោយព្រះរាជ ក្រមចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ១៩៩៤

ប្រការ ៣ : សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំ និង អនុវត្តការងារតាមការអញ្ជើញ របស់ប្រធានគណៈកម្មការ ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហ ប្រតិបត្តិការ អន្តរជាតិ រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃ ក្រសួងនិងស្ថាប័ន ដែលមានការពាក់ព័ន្ធ និង

អស់លោកដែលជាតំណាង ក្រសួងស្ថាប័នដែលមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

*រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ១៩៩៤*

## សេចក្តីសំរេចលេខ ១២១ សសរ

## ស្តីពីការបន្ថែមសមាសភាពគណៈកម្មការចំរុះដោះស្រាយបញ្ហាដីធ្លីអនាថាក្នុងរាជធានីភ្នំពេញ

* * *

## រដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-យោងសេចក្តីសំរេចលេខ ៣៣ សសរ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតគណៈកម្មការចំរុះដោះ ស្រាយបញ្ហាដីធ្លីអនាថា ក្នុងរាជធានីភ្នំពេញ ។

-យោងតាមការងារចាំបាច់ចំពោះមុខ